ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

-សំណុំរឿងព្រហ្មទណ្ឌលេខ៩១
ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១។
-សាលក្រមព្រហ្មទណ្ឌ
**លេខ ៧៩ "ឃ"**
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១។

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង០២ និង ០០ នាទីរសៀល នៅសាលទី២ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង។

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង។

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ម៉ៃ ភេទប្រុស អាយុ ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅ [redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃនៅ [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] ម៉ាង "ស" ម្តាយឈ្មោះ [redacted] អុន "ស" ប្រពន្ធឈ្មោះ [redacted] អៃ "រ" មានកូនចំនួន ០៤នាក់ ទោសពីមុនគ្មាន។

ជាប់ចោទពីបទ: **ប៉ុនប៉ងរំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅចំណុចភូមិឯលិច ឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ ២០២១ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ៃ។

**អង្គហេតុ នៃរឿងមានដូចតទៅ៖**

កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោងប្រហែល០៩ ឈ្មោះ [redacted] ម៉ៃ ភេទប្រុស អាយុ៥៧ឆ្នាំ រស់នៅភូមិឯលិច ឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង បានទៅខ្ចីស្នប់សប់កង់នៅផ្ទះរបស់ឈ្មោះ [redacted] នុន ដែលរស់នៅភូមិជាមួយគ្នា។ ពេលទៅដល់ ឈ្មោះ [redacted] ម៉ៃ បានឡើងទៅលើផ្ទះរបស់ឈ្មោះ [redacted] នុន ហើយបានឃើញជនរងគ្រោះឈ្មោះ [redacted] ណៃ ភេទស្រី អាយុ២៥ឆ្នាំ ជាមនុស្សសតិមិនគ្រប់ កំពុងដេកស្រាត ឈ្មោះ [redacted] ម៉ៃ ក៏បានឡើងពោបពីលើ ប្រុងធ្វើសកម្មភាពរំលោភសេពសន្ថវៈ តែត្រូវឈ្មោះ [redacted] នុន ឡើងមកទាន់ឈ្មោះ [redacted] ម៉ៃ ក៏ចុះទៅក្រោមវិញតែម្តង។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ម៉ៃ បានឆ្លើយសារភាពថា:ខ្លួនពិតជាមានចំណង់ផ្លូវភេទទៅលើឈ្មោះ [redacted] ណៃ ហើយចង់រំលោភប្រាកដមែន។ ដោយសារពេលខ្លួនឡើងទៅឃើញនាងដេកស្រាត។ខ្លួនមិនធ្លាប់ស្រលាញ់នាងពីមុនមកទេ។ ពេលឃើញបែបនេះ ខ្លួនបានរូតខោរបស់ខ្លួនឡើងពោបពីលើនាង ស្រាប់តែឈ្មោះ [redacted] នុន មកទាន់ ខ្លួនក៏ឈប់សកម្មភាពទៅ ហើយចុះមកលើដីជិះកង់ទៅផ្ទះដោយមិនបាននិយាយអ្វីទេ ហើយឈ្មោះ [redacted] នុន ក៏អត់និយាយអ្វីដែរ។/



Scanned with CamScanner

លុះដល់ម៉ោង៥ល្ងាច ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ឈ្មោះ [redacted] ណៃ ជាកូនរបស់ឈ្មោះ [redacted] នុន។ ឈ្មោះ [redacted] ណៃ ជាមនុស្សសតិមិនគ្រប់ អ្នកភូមិគេដឹងគ្រប់គ្នា។ពេលដែលខ្លួនប៉ះរំលោភ មិនបានគំរាមកំហែងទៅលើនាងទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] នុន បានឆ្លើយថា:នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៥ព្រឹក ខ្លួន និងប្តីបានចេញពីផ្ទះទៅធ្វើស្រែប្រាំងនៅភូមិដំណាក់កកោះ ឃុំពោធិ៍ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដោយទុកកូនស្រី ឈ្មោះ [redacted] ណៃ អាយុ២៥ឆ្នាំ មានសតិមិនគ្រប់ឱ្យនៅផ្ទះតែម្នាក់ឯង។ ដល់ម៉ោងប្រហែល ១៧ និង២០នាទី ខ្លួន និង ប្តីត្រឡប់មកផ្ទះវិញ ឈ្មោះ [redacted] គុន ភេទស្រី អាយុ៦០ឆ្នាំ បានមកប្រាប់ខ្លួនថា គាត់ឃើញឈ្មោះ [redacted] ម៉ៃ ជិះកង់មក ពីក្រៅហើយឡើងទៅលើផ្ទះរបស់ខ្លួន គាត់សង្ស័យក៏ឡើងទៅមើលឃើញឈ្មោះ [redacted] ម៉ៃ កំពុងតែនៅឯសំយាបផ្ទះ បាយ ឯក្រោយផ្ទះ រីឯកូនស្រីខ្លួនកំពុងតែលើកខោពាក់វិញ រួចខ្លួនក៏សង្ស័យហើយខ្លួនក៏បានសួរនាំកូនស្រី។

-ជនរងគ្រោះឈ្មោះ [redacted] ណៃ បានឆ្លើយថា: កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ព្រឹក ឪពុក របស់ខ្លួនទៅធ្វើស្រែប្រាំងអស់ ខ្លួនដេកនៅលើផ្ទះម្នាក់ឯង ឈ្មោះ [redacted] ម៉ៃ បានឡើងទៅលើផ្ទះរបស់ខ្លួន ហើយបានដេក ពីលើខ្លួន និងបានយកប្រដាប់ភេទដាក់ចូលប្រដាប់ភេទខ្លួនតិចៗ ហើយយាយគុនក៏មកទាន់ ឈ្មោះ [redacted] ម៉ៃ ក៏ដើបចុះពី លើផ្ទះទៅបាត់ទៅ។

-សាក្សីឈ្មោះ [redacted] គុន បានឆ្លើយថា:នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ព្រឹក ខ្លួនកំពុងអង្គុយពុះ អុសនៅក្រោមផ្ទះរបស់ខ្លួន ស្រាប់តែឃើញឈ្មោះ [redacted] ម៉ៃ ដើរមកពីក្រៅ ហើយឡើងទៅលើផ្ទះរបស់ឈ្មោះ [redacted] នុន (ប្តីប្រពន្ធ) នៅផ្ទះជាប់គ្នា បាត់ប្រហែលកន្លះម៉ោង ខ្លួនសង្ស័យក៏ដើរទៅមើលខ្លាចឈ្មោះ [redacted] ម៉ៃ លួចលុយ និងមាស របស់ឈ្មោះ [redacted] នុន។ ពេលឡើងទៅលើផ្ទះឃើញឈ្មោះ [redacted] ម៉ៃ កំពុងតែអង្គុយនៅចង្ក្រានបាយ និងឃើញក្មួយស្រី ខ្លួនឈ្មោះ [redacted] ណៃ ដែលមានសតិមិនគ្រប់ជាកូនស្រីរបស់ឈ្មោះ [redacted] នុន កំពុងតែលើកខោស្លៀកវិញ ។ ពេលនោះ ឈ្មោះ [redacted] ម៉ៃ ក៏ស្ទុះដើបចេញ ទៅផ្ទះបាត់ទៅ។ ពេលឪពុកម្តាយរបស់ឈ្មោះ [redacted] ណៃ មកពីធ្វើស្រែប្រាំងវិញ ខ្លួន ក៏និយាយរឿងរ៉ាវទាំងអស់ ហើយពួកគេក៏ទៅប្តឹងសមត្ថកិច្ចតែម្តង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ តំណាង អយ្យការសម្រេចតម្កល់ការចោទប្រកាន់ និងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា:ក្រោយពីបានសិក្សា លើសំណុំរឿង និងក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី,ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា កូនក្តីខ្លួនពិតជា បានទទួលកំហុស។ដូច្នេះសុំឱ្យតុលាការការបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំបាទផង។

- ជនជាប់ចោទឈ្មោះ [redacted] ម៉ៃ សុំឱ្យសុំតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាលើសំណុំរឿងចប់សព្វគ្រប់រួចមក

**យល់ឃើញថា÷**

១-ពិតជាមានអង្គហេតុនៃអំពើ ប៉ុនប៉ងរំលោភសេពសន្ថវៈ មួយបានកើតឡើង កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ប្រព្រឹត្តនៅភូមិឯលិច ឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង បង្កឡើងដោយឈ្មោះ [redacted] ម៉ៃ ភេទប្រុស អាយុ ៥៧ឆ្នាំ ប្រាកដមែន។

២-ជនជាប់ចោទឈ្មោះ [redacted] ម៉ៃ បានឆ្លើយសារភាពថា:ខ្លួនពិតជាមានចំណង់ផ្លូវភេទទៅលើឈ្មោះ [redacted] ណៃ ហើយចង់រំលោភប្រាកដមែន។ ដោយសារពេលខ្លួនឡើងទៅឃើញនាងដេកស្រាត។ ខ្លួនមិនធ្លាប់ស្រលាញ់នាងពីមុនមកទេ។ពេលឃើញបែបនេះ ខ្លួនបានរូតខោរបស់ខ្លួនឡើងពោបពីលើនាង ស្រាប់តែឈ្មោះ [redacted] តុន មកទាន់ ខ្លួនក៏ឈប់សកម្មភាពទៅ ហើយចុះមកលើដីជិះកង់ទៅផ្ទះដោយមិនបាននិយាយអ្វីទេ ហើយឈ្មោះ [redacted] តុន ក៏អត់និយាយអ្វីដែរ។ លុះដល់ម៉ោង៥ល្ងាច ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ឈ្មោះ [redacted] ណៃ ជាកូនរបស់ឈ្មោះ [redacted] នុន។ឈ្មោះ [redacted] ណៃ ជាមនុស្សសតិមិនគ្រប់ អ្នកភូមិគេដឹងគ្រប់គ្នា។ពេលដែលខ្លួនប៉ងរំលោភ មិនបានគំរាមកំហែងទៅលើនាងទេ។ចម្លើយនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៣-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **នុន** បានឆ្លើយថា:នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៥ព្រឹក ខ្លួននិងប្តីបានចេញពីផ្ទះទៅធ្វើស្រែប្រាំងនៅភូមិដំណាក់កកោះ ឃុំពោធិ៍ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដោយទុកកូនស្រីឈ្មោះ [redacted] ណៃ អាយុ២៥ឆ្នាំ មានសតិមិនគ្រប់ឲ្យនៅផ្ទះតែម្នាក់ឯង។ ដល់ម៉ោងប្រហែល ១៧ និង២០នាទី ខ្លួននិងប្តីត្រឡប់មកផ្ទះវិញ ឈ្មោះ [redacted] តុន ភេទស្រី អាយុ៦០ឆ្នាំ បានមកប្រាប់ខ្លួនថា គាត់ឃើញឈ្មោះ [redacted] ម៉ៃ ជិះកង់មកពីក្រៅហើយឡើងទៅលើផ្ទះរបស់ខ្លួន គាត់សង្ស័យក៏ឡើងទៅមើលឃើញឈ្មោះ [redacted] ម៉ៃ កំពុងតែនៅឯសំយាបផ្ទះបាយ ឯក្រោយផ្ទះ រីឯកូនស្រីខ្លួនកំពុងតែលើកខោពាក់វិញ រួចខ្លួនក៏សង្ស័យហើយខ្លួនក៏បានសួរនាំកូនស្រី។ចម្លើយនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៤-ជនរងគ្រោះឈ្មោះ [redacted] **ណៃ** បានឆ្លើយថា:កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ព្រឹក ឪពុករបស់ខ្លួនទៅធ្វើស្រែប្រាំងអស់ ខ្លួនដេកនៅលើផ្ទះម្នាក់ឯង ឈ្មោះ [redacted] ម៉ៃ បានឡើងទៅលើផ្ទះរបស់ខ្លួន ហើយបានដេកពីលើខ្លួន និងបានយកប្រដាប់ភេទដាក់ចូលប្រដាប់ភេទខ្លួនតិចៗ ហើយយាយតុនក៏មកទាន់ ឈ្មោះ [redacted] ម៉ៃ ក៏ងើបចុះពីលើផ្ទះទៅបាត់ទៅ។ចម្លើយនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៥-សាក្សីឈ្មោះ [redacted] **តុន** បានឆ្លើយថា:នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ០៩ព្រឹក ខ្លួនកំពុងអង្គុយពុះអុសនៅក្រោមផ្ទះរបស់ខ្លួន ស្រាប់តែឃើញឈ្មោះ [redacted] ម៉ៃ ដើរមកពីក្រៅ ហើយឡើងទៅលើផ្ទះរបស់ឈ្មោះ [redacted] នុន (ប្តីប្រពន្ធ) នៅផ្ទះជាប់គ្នា បាត់ប្រហែលកន្លះម៉ោង ខ្លួនសង្ស័យក៏ដើរទៅមើលខ្លាចឈ្មោះ [redacted] ម៉ៃ លួចលុយ និងមាសរបស់ឈ្មោះ [redacted] នុន។ ពេលឡើងទៅលើផ្ទះឃើញឈ្មោះ [redacted] ម៉ៃ កំពុងតែអង្គុយនៅចង្ក្រានបាយ និងឃើញក្មួយស្រីខ្លួនឈ្មោះ [redacted] ណៃ ដែលមានសតិមិនគ្រប់ជាកូនស្រីរបស់ឈ្មោះ [redacted] នុន កំពុងតែលើកខោស្លៀកវិញ ។ ពេលនោះ ឈ្មោះ [redacted] ម៉ៃ ក៏ស្ទុះងើបចេញ ទៅផ្ទះបាត់ទៅ។ ពេលឪពុកម្តាយរបស់ឈ្មោះ [redacted] ណៃ មកពីធ្វើស្រែប្រាំងវិញ ខ្លួនក៏និយាយរឿងរ៉ាវទាំងអស់ ហើយពួកគេក៏ទៅប្តឹងសមត្ថកិច្ចតែម្តង។ចម្លើយនេះគប្បីក្រុមប្រឹក្សាជំនុំជម្រះពិចារណា។

៦-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទ,ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី,ចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សីឃើញថា: អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ៃ ខាងលើមានធាតុផ្សំបទល្មើស គ្រប់គ្រាន់ពីបទ **ប៉ុនប៉ងរំលោភសេពសន្ថវៈ** តាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

៧-ជនជាប់ចោទខាងលើគឺជា **នីតិជន** ដែលមាននីតិសម្បទារគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយដែលជាមន្ទិល សង្ស័យថា ជននេះ មានបញ្ហាវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសឡើយ។ មួយវិញទៀតជនជាប់ចោទជា សមត្ថជន ដែលមានសមត្ថភាព មានការពិចារណា និងមានស្មារតីគ្រប់គ្រាន់អាចយល់ដឹងនូវអំពើនិងបច្ច័យដែលកើតឡើង ចំពោះអំពើ ប្រព្រឹត្តរបស់ខ្លួនក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ។

៨-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ម៉ៃ ភេទប្រុស អាយុ ៥៧ឆ្នាំ សញ្ជាតិ ខ្មែរ ពីបទ: **ម៉ុនម៉ាំងរំលោភសេពសន្ថវ**: ប្រព្រឹត្តនៅចំណុចភូមិឯលិច ឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាល ពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ម៉ៃ ភេទប្រុស អាយុ ៥៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់រយៈពេល ០៥ (ប្រាំ)ឆ្នាំ **ពីបទម៉ុនម៉ាំងរំលោភសេពសន្ថវ**: ប្រព្រឹត្តនៅចំណុចភូមិឯលិច ឃុំច្រណូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ តាមបញ្ញត្តិមាត្រា២៧ និងមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ម៉ៃ សងនូវសំណងជម្ងឺចិត្តជាប្រាក់ចំនួន ១,០០០,០០០ (មួយលាន)រៀល នៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]នុន។ការទាមទារលើសពីនេះត្រូវច្រានចោល។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ម៉ៃ និងដើមបណ្តឹងរដ្ឋប្បវេណី។

- ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមក្រុមប្រឹក្សា | ជំនុំជម្រះ |
|---|---|---|

ហត្ថលេខា និងត្រា: [redacted]

.......................................................................................................................

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

កំពង់ឆ្នាំង, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]